ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០១៧/២០ ក.ប/ស.ណ.ន.ក.ក.ស

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តវិធានការបង្ការជំងឺរលាកសួតដោយវីរុសកូវីដ-១៩ (Covid-19) និងជំងឺរលាកផ្លូវដង្ហើមដទៃទៀត នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

បច្ចុប្បន្នស្ថានភាពជំងឺរលាកសួតដោយវីរុស "កូវីដ-១៩" (Covid-19) បានរាតត្បាតនៅជុំវិញពិភពលោក ដោយមិនទាន់មានថ្នាំព្យាបាល ឬវ៉ាក់សាំងបង្ការជាផ្លូវការណាមួយនៅឡើយ ព្រមទាំងមានការផ្ទុះឡើងនៃជំងឺផ្តាសាយនានាដូចជា ផ្តាសាយបក្សី "H5N1" និងផ្តាសាយជ្រូក "H1N1" នៅតាមបណ្តាប្រទេសមួយចំនួននៅទ្វីបអាស៊ី និងក្នុងគោលបំណងជំរុញការអនុវត្តវិធានការបង្ការទប់ស្កាត់ជំងឺទាំងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអង្គភាពពាក់ព័ន្ធទាំងអស់អនុវត្តនូវវិធានការដូចខាងក្រោម៖

១. ត្រូវចាត់តាំងគណៈគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ១រូប ឱ្យទទួលបន្ទុកសណ្តាប់ធ្នាប់ និងការងារលើកកម្ពស់សុខភាព ដើម្បីអនុវត្តវិធានការឆ្លើយតបក្នុងការបង្ការទប់ស្កាត់ជំងឺរាតត្បាតខាងលើ។

២. ត្រូវពង្រឹងសណ្តាប់ធ្នាប់ចេញ-ចូលនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយពង្រឹងវិន័យ និងមិនឱ្យជនដែលគ្មានភារកិច្ចចេញ-ចូលដោយមិនមានការអនុញ្ញាត។

៣. ត្រូវរៀបចំឱ្យមានទឹកស្អាតទទួលទានជាប្រចាំសម្រាប់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត និងលើកទឹកចិត្តឱ្យយកទឹកស្អាតពីផ្ទះសម្រាប់ទទួលទានរៀងៗខ្លួន។

៤. ត្រូវរៀបចំឱ្យមានសាប៊ូ អាល់កុល ឬទឹកសម្លាប់មេរោគ សម្រាប់លាងដៃជាប្រចាំនៅច្រកចេញ-ចូលគ្រឹះស្ថាន បន្ទប់រៀន បន្ទប់ពិសោធន៍ រោងជាង បន្ទប់ទឹក និងបង្គន់អនាម័យ។

៥. ត្រូវដាស់តឿន និងរំលឹកជាប្រចាំដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ឱ្យពាក់ម៉ាស់ការពារក្នុងពេលដែលចាំបាច់ ឬនៅពេលដែលដឹងថាខ្លួនមានអាការៈមិនស្រួលខ្លួនដូចជា ក្តៅខ្លួន ផ្តាសាយ ក្អក ហៀរសំបោរ ជាដើម និងចៀសវាងការខាកស្តោះក្នុងកន្លែងធ្វើការ បន្ទប់រៀន បន្ទប់ពិសោធន៍ រោងជាង និងទីធ្លាសាធារណៈ។

៦. ត្រូវពិនិត្យលទ្ធភាពរៀបចំឧបករណ៍វាស់កម្តៅបុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅច្រកចេញ-ចូល ឬទីតាំងផ្សេងទៀតតាមការចាំបាច់ ករណីមានកម្តៅចាប់ពី ៣៨អង្សាសេ ត្រូវអនុញ្ញាតឱ្យឈប់សម្រាក ឬបញ្ជូនទៅទទួលសេវាព្យាបាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិត។

៧. ត្រូវតាមដាន និងពិនិត្យសុខភាពបុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ក្នុងករណីមានរោគសញ្ញាសង្ស័យដូចជា ក្អក កណ្តាស់ ក្តៅខ្លួន ផ្តាសាយ ហៀរសំបោរ

ឈឺក្បាល ឈឺបំពង់ក ដង្ហើមខ្លី និងពិបាកដកដង្ហើម ត្រូវណែនាំឱ្យទៅទទួលសេវាព្យាបាលទាន់ពេលវេលា ឬរាយការណ៍ទៅលេខទូរស័ព្ទទាន់ហេតុការណ៍១១៥។

៨. ត្រូវអប់រំផ្សព្វផ្សាយដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ឱ្យបង្កើនការយល់ដឹងអំពីការថែរក្សាសុខភាព និងយកចិត្តទុកដាក់នូវវិធានការដូចខាងក្រោម៖
- ចៀសវាងទៅទីផ្សារលក់សត្វរស់ ឬកន្លែងកសិដ្ឋានចិញ្ចឹមសត្វ ឬប៉ះពាល់សត្វព្រៃ ឬទៅកន្លែងដែលសង្ស័យថាមានមេរោគឆ្លង
- ទទួលទានទឹកឱ្យបានញឹកញាប់ យ៉ាងតិច២លីត្រក្នុង១ថ្ងៃ
- អ្នកមានអាការក្អក ឬកណ្តាស់ ត្រូវខ្ទប់មាត់ និងច្រមុះ ដោយប្រើកន្សែង ក្រមា ក្រដាស ឬយ៉ាងហោចណាស់ត្រូវប្រើគន្លាក់កែងដៃជំនួសបាតដៃ
- ចៀសវាងការប៉ះពាល់ភ្នែក ច្រមុះ ឬមាត់ ដោយដៃកខ្វក់
- កុំទៅទីប្រជុំជនដែលមានមនុស្សច្រើន ករណីចាំបាច់ត្រូវពាក់ម៉ាស់ ឬក្រមាគ្របលើមាត់ និងច្រមុះសម្រាប់បង្ការពីជំងឺឆ្លង
- លើកកម្ពស់ការគោរពគ្នាទៅវិញទៅមកដោយកាយវិការសំពះតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ
- ចម្អិនសាច់ និងស៊ុតគ្រប់ប្រភេទឱ្យបានឆ្អិនល្អ
- កុំប៉ះពាល់សត្វបក្សី សត្វចិញ្ចឹមគ្រប់ប្រភេទ ក្នុងករណីប៉ះផ្ទាល់ជាមួយសត្វទាំងនោះត្រូវលាងសម្អាតដៃជាមួយទឹកស្អាត សាប៊ូ អាល់កុល និងទឹកថ្នាំសម្លាប់មេរោគភ្លាម
- ប្រើប្រាស់ និងជឿជាក់លើប្រព័ន្ធព័ត៌មានដែលមានប្រភពច្បាស់លាស់
- ត្រូវបន្តអប់រំ និងផ្សព្វផ្សាយដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត អំពីវិធានការបង្ការ ការពារ និងសារអប់រំសុខភាពស្តីពីការការពារជំងឺរលាកសួតដោយវីរុស "កូវីដ-១៩" (Covid-19) ដែលចេញដោយក្រសួងសុខាភិបាល ឬរៀងរាល់ពេលដែលក្រសួងសុខាភិបាលចេញសេចក្តីណែនាំអំពីវិធានការបង្ការ ការពារ និងទប់ស្កាត់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ជានាយក នាយិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអង្គភាពពាក់ព័ន្ធទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តនូវខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃសុក្រ ១៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមីនា ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**
- សាលារាជធានី-ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទ
  "ដើម្បីជូនជ្រាប"
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ